ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្ត សៀមរាប

-សំណុំរឿងរដ្ឋប្បវេណីលេខ : ៤៣៥
ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៨
-ឈ្មោះរឿងក្តី : ប្តឹងទាមទារប្រាក់
-សាលក្រមលេខ : ០៥ "ច"
ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៩

## នាមនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងខេត្តសៀមរាប

បានធ្វើនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់នៅបន្ទប់សវនាការលេខ ០២
បានដំណើរការនីតិវិធីទាញហេតុផលផ្ទាល់មាត់នៅថ្ងៃអង្គារ ៨កើត ខែមាឃ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៩ វេលា រសៀល។
បានបញ្ចប់នីតិវិធីទាញហេតុផលផ្ទាល់មាត់នៅថ្ងៃអង្គារ ៨កើត ខែមាឃ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៩ វេលា រសៀល ។
កាលបរិច្ឆេទប្រកាសនៅថ្ងៃអង្គារ ៧រោច ខែមាឃ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៩ វេលា ព្រឹក ។

## ចៅក្រមជំនុំជម្រះ

លោក [redacted] ចៅក្រមនៃសាលាដំបូង ខេត្តសៀមរាប ។

## ក្រឡាបញ្ជីសវនាការ

លោកស្រី [redacted] ក្រឡាបញ្ជីនៃសាលាដំបូង ខេត្តសៀមរាប ។

-ដើមចោទឈ្មោះ [redacted]ហ៊ាង ភេទប្រុស អាយុ ៦០ឆ្នាំ សញ្ជាតិ ខ្មែរ អាសយដ្ឋានបច្ចុប្បន្ននៅភូមិ [redacted]។
មានលោកមេធាវី [redacted]និងលោក [redacted]សារ៉ាវុទ្ធ ជាអ្នកតំណាងដោយអាណត្តិ
-ចុងចម្លើយឈ្មោះ [redacted]ណាសុង ភេទប្រុស អាយុ ៣៧ឆ្នាំ សញ្ជាតិ ខ្មែរ អាសយដ្ឋានបច្ចុប្បន្ន [redacted]
មានលោកមេធាវី [redacted] និងលោកមេធាវី [redacted]ជាអ្នកតំណាងដោយអាណត្តិ

## អង្គហេតុ និង ចំណុចវិវាទ :

ក - សាលក្រមទាមទារដោយដើមចោទ :

ដើមចោទទាមទារឱ្យសាលាដំបូងខេត្តសៀមរាប ចេញសាលក្រមសម្រេចដូចតទៅ :

១-ឲ្យចុងចម្លើយឈ្មោះ [redacted]ណាសុង សងប្រាក់ជំពាក់ចំនួន $៧០,០០០ (ប្រាំពីរម៉ឺនដុល្លារអា-មេរិក)។

២-ឲ្យចុងចម្លើយសងការខូចខាតចំនួន $២០,០០០ (ពីរម៉ឺនដុល្លារអាមេរិក) មកឲ្យដើមចោទ។

៣-ឲ្យចុងចម្លើយសងប្រាក់ជំពាក់បន្ថែមចំនួន ៣៩,២៤៣,៤០០៛ (សាមសិបប្រាំបួនលានពីររយសែសិបបីពាន់បួនរយរៀល) មកឲ្យដើមចោទ។

៤-ឲ្យប្រកាសអនុវត្តជាបណ្តោះអាសន្នគ្រង់ការទាមទារចំណុចទី១។



Scanned with CamScanner

៥-ឲ្យចុងចម្លើយជាអ្នកទទួលបន្ទុកប្រាក់ប្រដាប់ក្តី។

ខ - សាលក្រមទាមទារដោយចុងចម្លើយ :

ចុងចម្លើយទាមទារឱ្យសាលាដំបូងខេត្តសៀមរាប ចេញសាលក្រមសម្រេចដូចតទៅ :

១-ច្រានចោលពាក្យបណ្តឹង ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៨ របស់ឈ្មោះ [redacted] ហ៊ាង ជាអសារបង់។

២-ឲ្យឈ្មោះ [redacted] ហ៊ាង សងសំណងថ្លៃរំលោភកិច្ចសន្យាព្រមព្រៀង ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ ២០១៧ ធ្វើឡើងរវាងដើមចោទ និងចុងចម្លើយ ព្រមទាំងថ្លៃខាតបង់ពេលវេលា, ថ្លៃចំណាយលើសេវាកម្មច្បាប់ និងការចំណាយផ្សេងៗ សរុបចំនួន $២០.០០០(ពីរម៉ឺនដុល្លារអាមេរិក) ឲ្យទៅឈ្មោះ [redacted] ណាសុង ។

៣-ឲ្យឈ្មោះ [redacted] ហ៊ាង ទទួលបន្ទុកប្រាក់ប្រដាប់ក្តី។

គ-ការពន្យល់ត្រួសៗអំពីដំណើររឿងក្តី :

កាលពីថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៧ ដើមចោទ និងចុងចម្លើយឈ្មោះ [redacted] ណាសុង បានបង្កើតកិច្ចព្រមព្រៀងមួយចំពោះមុខចៅសង្កាត់សៀមរាប ស្តីពីការទទួលស្គាល់បំណុលចំនួន ៧០,០០០ (ប្រាំពីរម៉ឺន) ដុល្លារអាមេរិក ដោយឈ្មោះ [redacted] ណាសុង សុខចិត្តប្រគល់ត្រីក្នុងស្រះទាំងអស់ទៅឲ្យដើមចោទលក់ដើម្បីទូទាត់បំណុលនៅពេលដែលត្រីនោះអាចចាប់លក់បាន។ ក្រោយពេលដែលព្រមព្រៀងគ្នារួច ដើមចោទ គឺជាអ្នករ៉ាប់រងរាល់ការចំណាយក្នុងការដាក់ចំណីត្រីដែលមានក្នុងស្រះទាំងអស់ជំនួសឈ្មោះ [redacted] ណាសុង។ បន្ទាប់ពីដាក់ចំណីត្រីមួយរយៈពេលមក គឺមកដល់ពេលដែលត្រូវចាប់ត្រីលក់ ដើមចោទបានចាប់ត្រីលក់ដើម្បីទូទាត់បំណុលក្នុងការលក់ខាងលើបានប្រាក់សរុបចំនួន ៨៦,៦៧៩,០០០ (ប៉ែតសិបប្រាំមួយលានប្រាំមួយសែនប្រាំពីរម៉ឺនប្រាំបួនពាន់)រៀល ប្រាក់ដែលបានមកពីការលក់ត្រីនេះ ដើមចោទបានយកទៅសងឈ្មោះ [redacted] មិន អស់ចំនួន ៣០,០០០,០០០ (សាមសិបលាន)រៀល ដែលឈ្មោះ [redacted] ណាសុង បានជំពាក់ចំនួន ៥០,០០០,០០០ (ហាសិបលាន)រៀល ដោយមានដើមចោទជាអ្នកធានាបំណុល និងទូទាត់ជាមួយថ្លៃចំណីត្រីចំនួន ៧៥,៩២២,៤០០ (ចិតសិបប្រាំលានប្រាំបួនសែនពីរម៉ឺនពីរពាន់បួនរយ)រៀល ដូច្នេះចុងចម្លើយនៅជំពាក់ប្រាក់ដើមចោទចំនួន ៣៩,២៤៣,៤០០ (សាមសិបប្រាំបួនលានពីរសែនបួនម៉ឺនបីពាន់បួនរយ)រៀល បន្ថែមលើប្រាក់ដែលទទួលស្គាល់ចំពោះបំណុលលើកមុនចំនួន ៧០,០០០ (ប្រាំពីរម៉ឺន)ដុល្លារអាមេរិកទៀត។

ឃ-ការអះអាងរបស់គូភាគី:

- ដើមចោទបានធ្វើសេចក្តីថ្លែងការណ៍ថា៖ ខ្ញុំនៅតែរក្សាការទាមទារដូចនៅក្នុងពាក្យបណ្តឹង និងនៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលទាំងពីរលើកដដែល។

- អ្នកតំណាងដោយអាណត្តិរបស់ដើមចោទបានធ្វើសេចក្តីថ្លែងការណ៍ថា៖ ក្នុងនាមជាអ្នកតំណាងដោយអាណត្តិរបស់ដើមចោទ ខ្ញុំសុំរក្សាការទាមទារដូចកម្មវត្ថុបណ្តឹង ក្នុងពាក្យបណ្តឹងចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ ២០១៨ និងពាក្យសុំបន្ថែមកម្មវត្ថុបណ្តឹងចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៨ ទុកជាបានការដដែល។ ចំពោះអង្គហេតុ និងមូលហេតុនៃការទាមទារមានដូចតទៅ៖

១.អំពីការទាមទារឱ្យចុងចម្លើយឈ្មោះ [redacted] ណាសុង សងប្រាក់ដើមជំពាក់ចំនួន ៧០,០០០(ប្រាំពីរម៉ឺន)ដុល្លារអាមេរិក និងជំពាក់បន្ថែមទៅលើការចំណាយទិញត្រីនុយចំនួន ៣៩,២៤៣,៤០០ (សាមសិបប្រាំបួនលានពីរសែនបួនម៉ឺនបីពាន់បួនរយ)រៀល មកឱ្យដើមចោទ ដោយហេតុថា កាលពីថ្ងៃទី២៤ ខែតុលា ឆ្នាំ ២០១៧ ចុងចម្លើយឈ្មោះ [redacted] ណាសុង បានចុះកិច្ចសន្យាព្រមព្រៀងទទួលស្គាល់បំណុលជាមួយកូនក្តីខ្លួន



Scanned with CamScanner

ចំនួន ៧០,០០០ (ប្រាំពីរម៉ឺន) ដុល្លារអាមេរិក ដោយចុងចម្លើយបានព្រមព្រៀងប្រគល់ត្រីក្នុងស្រះទាំងអស់មកអោយកូនក្តីខ្លួន ដើម្បីលក់ទូទាត់បំណុលនេះ ហើយបានសន្យាថា បើលក់ត្រីឆ្នាំនេះទូរទាត់មកកូនក្តីខ្លួនមិនគ្រប់ចំនួនទេ ចុងចម្លើយនឹងធ្វើការទូទាត់នៅឆ្នាំក្រោយបន្តទៀត ដោយកូនក្តីខ្លួនមិនគិតអំពីការប្រាក់ឡើយដោយចុងចម្លើយអះអាងថា ត្រីនៅក្នុងស្រះរបស់ខ្លួនមានចំនួនជាង៣០ ទៅ ៤០ តោនឯនោះ ហើយក៏បានធ្វើកិច្ចព្រមព្រៀងដោយមានលោកចៅសង្កាត់សៀមរាបឈ្មោះ [redacted] ម៉ាក់យូរី ព្រមទាំងសាក្សីឈ្មោះ [redacted] ផា និងឈ្មោះ [redacted] គឹមភ័ណ្ឌ បានឃើញ និងដឹងឮផងដែរ ដូចមាននៅក្នុងកិច្ចព្រមព្រៀងស្រាប់។ នៅក្នុងខែតុលា ឆ្នាំ២០១៧ នេះផងដែរ ចុងចម្លើយបានទៅអង្វរកូនក្តីខ្លួនឱ្យជួយចេញសងបំណុលជំនួសខ្លួនដែលខ្លួនបានជំពាក់ឈ្មោះ [redacted] [redacted] មិន ចំនួន ៥០,០០០,០០០ (ហាសិបលាន)រៀល ដោយមានការយោគយល់កូនក្តីខ្លួនក៏បានយល់ព្រមដោយធ្វើការផ្ទេរបំណុលនោះមកកូនក្តីខ្លួនវិញ ដូចមានក្នុងកិច្ចព្រមព្រៀង ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៧ ភ្ជាប់មកជាមួយស្រាប់។ បន្ទាប់ពីធ្វើកិច្ចព្រមព្រៀងទទួលស្គាល់បំណុលរវាងចុងចម្លើយ និងកូនក្តីខ្លួន រួចមក ឃើញរាល់ការចំណាយទាំងឡាយទៅលើចំណីត្រីរហូតដល់ថ្ងៃចាប់ត្រីលក់នោះ គឺកូនក្តីខ្លួនជាអ្នកទទួលរាប់រងចេញជំនួសឱ្យចុងចម្លើយទាំងអស់ដោយរង់ចាំទូទាត់ពេលលក់ត្រីរួចរាល់ ចំពោះការចំណាយសរុបអស់ចំនួន ៦៨,៥៣៥,២០០ (ហុកសិបប្រាំលានប្រាំ សែនបីម៉ឺនប្រាំពាន់ពីររយ)រៀល ដោយមានវិក័យប័ត្រទូទាត់ត្រឹមត្រូវភ្ជាប់មកជាមួយ។ ជាក់ស្តែងដល់ថ្ងៃត្រូវ ចាប់ត្រីលក់នោះ គឺត្រីនៅក្នុងស្រះចាប់បានតែចំនួន ១០,៤៤០(មួយម៉ឺនបួនរយសែសិប) គីឡូ ស្មើជាង១០តោន តែប៉ុណ្ណោះ គិតជាប្រាក់បានចំនួន ៨៦,៦៧៩,០០០( ប៉ែតសិបប្រាំមួយលានប្រាំមួយសែនប្រាំពីរម៉ឺនប្រាំបួនពាន់)រៀល ចំពោះប្រាក់ដែលបានមកពីការលក់ត្រីនេះ ត្រូវយកទៅទូទាត់ជាមួយចំណីត្រីបានចំនួនខាងលើ ដូច្នេះនៅសល់ ១០,៧៥៦,៦០០ (ដប់លានប្រាំពីរសែនប្រាំម៉ឺនប្រាំមួយពាន់ប្រាំមួយរយ)រៀល។ បន្ទាប់ កូនក្តីខ្លួនត្រូវមានកាតព្វកិច្ចសងបំណុលជំនួសឈ្មោះ [redacted] ណាសុង ដែលជំពាក់ឈ្មោះ [redacted] មិន តាមការព្រមព្រៀង កន្លងមកដែលការអនុវត្តកាតព្វកិច្ចនេះ កូនក្តីខ្លួនបានសងទៅឈ្មោះ [redacted] មិន បានចំនួន ៣០,០០០,០០០ (សាមសិបលាន)រៀល តែប៉ុណ្ណោះ នៅខ្វះចំនួន ២០,០០០,០០០ (ម្ភៃលាន)រៀល ទៀតដែលត្រូវអនុវត្តបន្ត ដូច្នេះកូនក្តីខ្លួនមានសិទ្ធិលើបំណុលចំពោះចុងចម្លើយចំនួន ៣៩,២៤៣,៤០០ (សាមសិបប្រាំបួនលានម្ភៃបួនម៉ឺនបីពាន់បួនរយ)រៀល បន្ថែមលើបំណុលចាស់ដែលចុងចម្លើយទទួលស្គាល់។

២.អំពីការទាមទារឱ្យចុងចម្លើយបង់ការខូចខាតចំនួន ២០,០០០ (ពីរម៉ឺន) ដុល្លារអាមេរិកមកឱ្យដើមចោទ ប្រាក់ដែលកូនក្តីខ្លួនឱ្យចុងចម្លើយខ្ចី ជាប្រាក់ដែលខ្ចីពីធនាគារត្រូវអនុវត្តករណីយកិច្ចសងប្រាក់ដើម និងការប្រាក់ទៅធនាគារវិញ។ ម្យ៉ាងទៀត បានធ្វើឱ្យកូនក្តីខ្លួនខាតបង់ពេលវេលា និងប្រាក់ជាច្រើនក្នុងការដោះស្រាយដំណើររឿងក្តីនៅតុលាការ។

៣.អំពីការទាមទារសុំប្រកាសឱ្យអនុវត្តបណ្តោះអាសន្នត្រង់ចំណុចទី១ នៃការទាមទារៈ ក្នុងនាមអ្នកតំណាងដោយអាណត្តិខ្លួនសូមធ្វើការទាមទារសុំឲ្យតុលាការធ្វើការអនុវត្តជាបណ្តោះអាសន្នត្រង់ចំណុចទី១ ដោយហេតុថាដើមចោទត្រូវតែទទួលបានមកវិញនូវប្រាក់ដើមទាំងអស់នេះឱ្យបានឆាប់រហ័ស បើពុំមានការប្រកាសឱ្យអនុវត្តបណ្តោះអាសន្ននោះទេ ដើមចោទកាន់តែខូចផលប្រយោជន៍យ៉ាងធ្ងន់ធ្ងរ ហើយចំពោះប្រាក់ប្រដាប់ក្តី គឺចុងចម្លើយជាអ្នកទទួលបន្ទុក ដោយហេតុថារាល់ការចំណាយផ្សេងៗទៅលើបណ្តឹងនេះ គឺជាកំហុសរបស់ចុងចម្លើយទាំងស្រុង។



Scanned with CamScanner

-ចុងចម្លើយបានធ្វើសេចក្ដីថ្លែងការណ៍ថា៖រឿងធានាប្រាក់ឈ្មោះ [redacted] មិន គឺខ្លួនអត់បានឲ្យគាត់ធានាទេ ពេលគាត់ (ដើមចោទ) និងឈ្មោះ [redacted] មិន ចាប់ត្រីខ្លួន ខ្លួនលក់ត្រីស្រះទី២នោះ ឈ្មោះ [redacted] មិន ទារឲ្យខ្លួនសង ២០០,០០០,០០០ (ម្ភៃលាន)រៀល តែខ្លួនថាអត់បានទេ ត្រីស្រះទី២នេះ គឺខ្លួនលក់សងឈ្មោះ [redacted] ហ៊ាង ខ្ញុំមិនបានឲ្យដើមចោទសងទៅឈ្មោះ [redacted] មិន ចំនួន ៣០០,០០០,០០០(សាមសិបលាន)រៀលនោះទេ។ រឿងត្រីនុយខ្លួនមិនទទួលស្គាល់ទេ ព្រោះខ្លួនអត់មានស្នាមមេដៃ ចំណែកការព្រមព្រៀងនៅចៅសង្កាត់ខ្លួនទទួលស្គាល់។

-លោក [redacted] អ្នកតំណាងដោយអាណត្តិរបស់ចុងចម្លើយបានធ្វើសេចក្ដីថ្លែងការណ៍ថា៖ ខ្ញុំសូមរក្សានូវខ្លឹមសារ ការអះអាងក្នុងកំណត់ហេតុស្ដីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៨ និងកំណត់ហេតុស្ដីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៩ ទុកជាបានការដដែល និងប្ដឹងសុំឲ្យតុលាការច្រានចោលការទាមទាររបស់ដើមចោទទាំងស្រុង ដោយសារការការទាមទាររបស់ដើមចោទមានការលើសលុបដោយគ្មានមូលដ្ឋានគ្រប់គ្រាន់។ តាមកិច្ចសន្យាកូនក្ដីខ្ញុំបានខ្ចីដើមចោទចំនួន ២លើក លើកទី១ចំនួន ៥០០០០(ប្រាំម៉ឺន)ដុល្លារអាមេរិក និងលើកទី២ ចំនួន ៤០០០(បួនពាន់)ដុល្លារអាមេរិក សរុបចំនួន ៥៤០០០ (ប្រាំម៉ឺនបួនពាន់)ដុល្លារអាមេរិក តែកូនក្ដីខ្ញុំបានលក់ត្រីសងបានចំនួន ៨៦,៦៧៩,០០០ (ប៉ែតសិបប្រាំមួយលានហុកសិប្រាំពីរម៉ឺនប្រាំបួនពាន់)រៀល រួចហើយ ហេតុនេះនៅសល់តែ ៣០,១៤៩ (បីម៉ឺនមួយរយសែសិបប្រាំបួន)ដុល្លារអាមេរិក ហើយសុំច្រានចោលភស្តុតាងដែលដើមចោទដាក់ជូនតុលាការទាំងអស់ និងបដិសេធអង្គហេតុជំពាក់ប្រាក់រវាងដើមចោទ និងឈ្មោះ [redacted] មិន និងកូនក្ដីខ្ញុំ សុំឲ្យតុលាការចេញសាលក្រមសងជំងឺចិត្តចំនួន ២០,០០០(ពីរម៉ឺន)ដុល្លារអាមេរិក ដោយសារកូនក្ដីខ្ញុំខ្ចី ៥៤០០០ (ប្រាំម៉ឺនបួនពាន់)ដុល្លារអាមេរិក តែបានធ្វើការទទួលស្គាល់បំណុល ៧០០០០ (ប្រាំពីរម៉ឺ)ដុល្លារអាមេរិក ដោយមានលក្ខខណ្ឌ២ ទី១គឺកូនក្ដីខ្ញុំប្រគល់ត្រីក្នុងស្រះដើម្បីលក់ទូទាត់បំណុល ហើយគាត់បានទទួលស្គាល់ថាកូនក្ដីខ្ញុំបានលក់ត្រីបានលុយ ៨៦លានរៀលមែន ទី២គឺលុយដែលនៅសល់ កូនក្ដីខ្ញុំនឹងសងនៅឆ្នាំក្រោយ តែមិនទាន់ដល់ឆ្នាំក្រោយដើមចោទបែរជាដាក់ពាក្យបណ្ដឹងប្ដឹងទាមទារប្រាក់ពីកូនក្ដីខ្លួនទៀត។

-លោក [redacted] អ្នកតំណាងដោយអាណត្តិរបស់ចុងចម្លើយបានធ្វើសេចក្ដីថ្លែងការណ៍ថា៖ ប្រាក់ដើមដែលកូនក្ដីខ្ញុំបានខ្ចីពីដើមចោទ គឺមានចំនួនតែ ៥៤០០០ (ប្រាំម៉ឺនបួនពាន់)ដុល្លារអាមេរិក តែគាត់ខកខានបង់ទើបគាត់ធ្វើការទទួលស្គាល់បំណុល ៧០០០០ (ប្រាំពីរម៉ឺន)ដុល្លារអាមេរិក ហើយការកាត់ត្រីលក់នេះ គឺបានចំនួន ជាង៨៦លានរៀលហើយ ហេតុនេះ សុំទទួលស្គាល់តែ ជាង៣ម៉ឺនដុល្លារអាមេរិក តែប៉ុណ្ណោះ។ ហើយភស្តុតាងដែលដើមចោទដាក់មក គឺពុំមានទំនាក់ទំនងគតិយុត្តិជាមួយកូនក្ដីខ្ញុំបាទទេ។

-អ្នកតំណាងដោយអាណត្តិរបស់ដើមចោទបានធ្វើសេចក្ដីថ្លែងការណ៍ថា៖ ខ្ញុំសុំច្រានចោលការទាមទាររបស់ចុងចម្លើយទាំងស្រុង ដោយហេតុថាពុំមានភាពត្រឹមត្រូវតាមច្បាប់ ហើយការទទួលស្គាល់បំណុល ៧០០០០ (ប្រាំពីរម៉ឺន)ដុល្លារអាមេរិក គឺកើតចេញពីឆន្ទៈពិតប្រាកដពុំមានការបង្ខិតបង្ខំឡើយ។ ហេតុនេះ ខ្ញុំសុំច្រានចោលបណ្ដឹងតប និងសុំរក្សាការទាមទារដដែល។

-អ្នកតំណាងដោយអាណត្តិរបស់ចុងចម្លើយបានធ្វើសេចក្ដីសន្និដ្ឋានថា៖ ចំពោះកិច្ចសន្យាធានា គឺពិតជាបានធ្វើមែន តែប្រាក់ ៣០លានរៀលនោះ គឺកូនក្ដីខ្ញុំមិនបានដឹងថាដើមចោទ សងទៅឈ្មោះ [redacted] មិន ទេ។

<u>ង.ចំណុចវិវាទ៖</u>

<u>ចំណុចមានវិវាទ ៖</u>

១.ចុងចម្លើយមិនទទួលស្គាល់ការទាមទារប្រាក់ដើមចំនួន ៧០០០០(ប្រាំពីរម៉ឺន)ដុល្លារអាមេរិក

២.ចុងចម្លើយមិនទទួលស្គាល់ការទាមទារប្រាក់ត្រីនុយចំនួន ៣៩២៤៣៤០០ រៀល

៣.ចុងចម្លើយមិនទទួលស្គាល់ការទាមទារសំណងការខូចខាតចំនួន ២០០០០ (ពីរម៉ឺន)ដុល្លារអាមេរិក

៤.ដើមចោទប្រានចោលការទាមទារសំណងការរំលោភកិច្ចសន្យាចំនួន ២០០០០ (ពីរម៉ឺន)ដុល្លារអាមេរិក

៥.ដើមចោទសុំឲ្យចុងចម្លើយទទួលបន្ទុកប្រាក់ប្រដាប់ក្តី ចុងចម្លើយប្រានចោល

៦.ដើមចោទសុំប្រកាសអនុវត្តបណ្តោះអាសន្នលើប្រាក់ ៧០០០០(ប្រាំពីរម៉ឺន)ដុល្លារអាមេរិក ចុងចម្លើយប្រានចោល។

ចំណុចគ្មានវិវាទ៖ គ្មាន

**សំអាងហេតុ :**

ឆ្លងតាមលទ្ធផលនៃការសាកសួរគូភាគី និងការពិនិត្យភស្តុតាងនានា នៅក្នុងកាលបរិច្ឆេទទាញហេតុផលដោយផ្ទាល់មាត់ តុលាការយល់ឃើញថា៖

១-ពាក្យបណ្តឹងចុះថ្ងៃទី ១៥ ខែសីហា ឆ្នាំ២០១៨ របស់ដើមចោទឈ្មោះ [redacted] ហ៊ាង, ពាក្យសុំបន្ថែមកម្មវត្ថុនៃពាក្យបណ្តឹង ចុះថ្ងៃទី ១៨ ខែធ្នូ ឆ្នាំ២០១៨ របស់អ្នកតំណាងដោយអាណត្តិអោយដើមចោទ និងពាក្យបណ្តឹងតប ចុះថ្ងៃទី ២០ ខែកញ្ញា ឆ្នាំ២០១៨ របស់ចុងចម្លើយឈ្មោះ [redacted] ណាសុង ធ្វើឡើងមានលក្ខណៈត្រឹមត្រូវតាមច្បាប់ ដែលអាចឲ្យតុលាការធ្វើការពិចារណាបាន។

២-ដើមចោទទាមទារឲ្យសហចុងចម្លើយសងប្រាក់ដើមចំនួន USD ៧០,០០០ (ប្រាំពីរម៉ឺនដុល្លារអាមេរិក) ដោយហេតុថា កាលពីថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៧ ចុងចម្លើយឈ្មោះ [redacted] ណាសុង បានចុះកិច្ចសន្យាព្រមព្រៀងទទួលស្គាល់បំណុលជាមួយកូនក្តីខ្លួនចំនួន ៧០,០០០ (ប្រាំពីរម៉ឺន) ដុល្លារអាមេរិក ដោយចុងចម្លើយបានព្រមព្រៀងប្រគល់ត្រីក្នុងស្រះទាំងអស់មកអោយកូនក្តីខ្លួន ដើម្បីលក់ទូទាត់បំណុលនេះ ហើយបានសន្យាថា បើលក់ត្រីឆ្នាំនេះទូរទាត់មកកូនក្តីខ្លួនមិនគ្រប់ចំនួនទេ ចុងចម្លើយនឹងធ្វើការទូទាត់នៅឆ្នាំក្រោយបន្តទៀត ដោយកូនក្តីខ្លួនមិនគិតអំពីការប្រាក់ឡើយដោយចុងចម្លើយអះអាងថា ត្រីនៅក្នុងស្រះរបស់ខ្លួនមានចំនួនជាង ៣០ ទៅ ៤០ តោនឯនោះ ហើយក៏បានធ្វើកិច្ចព្រមព្រៀងដោយមានលោកចៅសង្កាត់សៀមរាបឈ្មោះ [redacted] ម៉ាក់យូរី ព្រមទាំងសាក្សីឈ្មោះ [redacted] ផា និងឈ្មោះ [redacted] គឹមភ័ណ្ឌ បានឃើញ និងដឹងឮផងដែរ ដូចមាននៅក្នុងកិច្ចព្រមព្រៀង ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៧។ ឃើញថាការទាមទាររបស់ដើមចោទនេះ ត្រូវបានចុងចម្លើយប្រានចោល ដោយទទួលថាបានជំពាក់ប្រាក់ដើមចោទចំនួន តែ ៥៤០០០ (ប្រាំម៉ឺនបួនពាន់) ដុល្លារអាមេរិកប៉ុណ្ណោះ និងបានលក់ត្រីសងអស់ចំនួន៨៦,៦៧៩,០០០ (ប៉ែតសិបប្រាំមួយលានហុកសិប្រាំពីរម៉ឺនប្រាំបួនពាន់) រៀល រួចហើយ ហេតុនេះនៅសល់តែ ៣០,១៤៩ (បីម៉ឺនមួយរយសែសិបប្រាំបួន)ដុល្លារអាមេរិកនោះទេ។ ប៉ុន្តែតាមកិច្ចព្រមព្រៀង ចុះថ្ងៃទី ២៤ ខែតុលា ឆ្នាំ២០១៧ ឃើញថា ចុងចម្លើយឈ្មោះ [redacted] ណាសុង បានព្រមព្រៀងទទួលស្គាល់បំណុលជំពាក់ដើមចោទ ឈ្មោះ [redacted] ហ៊ាង ចំនួន USD ៧០,០០០ (ប្រាំពីរម៉ឺនដុល្លារអាមេរិក) ហើយចុងចម្លើយក៏បានថ្លែងអះអាងទទួលស្គាល់ថាពិតជាបានចុះកិច្ចព្រមព្រៀងខាងលើ ជាមួយដើមចោទប្រាកដមែន ម្យ៉ាងទៀត ការចុះកិច្ចព្រមព្រៀង ចុះថ្ងៃ ទី២៤ ខែតុលា ឆ្នាំ២០១៧ រវាងដើមចោទ និងចុងចម្លើយ គឺកើតឡើងពីឆន្ទៈពិតប្រាកដពុំមានការបង្ខិតបង្ខំឡើយ ហេតុនេះ តុលាការគប្បីសម្រេចទទួលស្គាល់ការទាមទាររបស់ដើមចោទ។

៣-អ្នកតំណាងដោយអាណត្តិរបស់ដើមចោទបានថ្លែងថា ដើមចោទទាមទារឲ្យចុងចម្លើយសងប្រាក់ជំពាក់បន្ថែម ៣៩,២៤៣,៤០០ (សាមសិបប្រាំបួនលានម្ភៃបួនម៉ឺនបីពាន់បួនរយ)រៀល ដោយមូលហេតុថា នៅក្នុងខែតុលា ឆ្នាំ២០១៧នេះផងដែរ ចុងចម្លើយបានទៅអង្វរកូនក្តីខ្លួនឱ្យជួយចេញសងបំណុលជំនួសខ្លួន ដែលខ្លួនបានជំពាក់ឈ្មោះ [redacted] មិន ចំនួន ៥០,០០០,០០០ (ហាសិបលាន)រៀល ដោយមានការយោគយល់



Scanned with CamScanner

កូនក្តីខ្លួនក៏បានយល់ព្រមដោយធ្វើការផ្ទេរបំណុលនោះមកកូនក្តីខ្លួនវិញ ដូចមានក្នុងកិច្ចព្រមព្រៀង ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៧ ភ្ជាប់មកជាមួយស្រាប់ ហេតុនេះកូនក្តីខ្លួនត្រូវមានកាតព្វកិច្ចសងបំណុលទៅឲ្យឈ្មោះ [redacted] មិន ជំនួសចុងចម្លើយឈ្មោះ [redacted] ណាសុង។ អ្នកតំណាងដោយអាណត្តិរបស់ដើមចោទក៏បានបញ្ជាក់បន្ថែមដែរថា លុយដែលបានមក ពីការលក់ត្រីក្នុងស្រះ ដែលចុងចម្លើយដាក់ធានាប្រាក់បំណុលកូនក្តីខ្លួនបានចំនួន ៨៦,៦៧៩,០០០ (ប៉ែតសិបប្រាំមួយលានប្រាំមួយសែនប្រាំពីរម៉ឺនប្រាំបួន)រៀលនោះ គឺមិនបានយកមកទូទាត់សងបំណុលចំនួន ៧០,០០០ (ប្រាំពីរម៉ឺន)ដុល្លារអាមេរិកដែលចុងចម្លើយជំពាក់ខ្លួននោះទេ គឺត្រូវយកទៅទូទាត់ជាមួយថ្លៃត្រីនុយអស់ចំនួន ៦៨,៥៣៥,២០០ (ហុកសិបប្រាំបីលានប្រាំសែនបីម៉ឺនប្រាំពាន់ពីររយ) រៀល និងលុយដែលនៅសល់ចំនួន ១០,៧៥៦,៦០០ (ដប់លានប្រាំពីរសែនប្រាំម៉ឺនប្រាំមួយពាន់ប្រាំមួយរយ)រៀល គឺយកទៅទូទាត់បំណុលឈ្មោះ [redacted] មិន ដែលកូនក្តីខ្លួនត្រូវសងជំនួសចុងចម្លើយ ហើយកន្លងមក គឺកូនក្តីខ្លួនបានសងជំនួសចុងចម្លើយឱ្យទៅឈ្មោះ [redacted] មិន អស់ចំនួន ៣០,០០០,០០០ (សាមសិបលាន)រៀល នៅសល់ចំនួន ២០,០០០,០០០ (ម្ភៃលាន)រៀលទៀត ដែលត្រូវអនុវត្តបន្តដូច្នេះកូនក្តីខ្លួនមានសិទ្ធិលើបំណុលចំពោះចុងចម្លើយចំនួន ៣៩,២៤៣,៤០០ (សាមសិបប្រាំបួនលានពីរសែនបួនម៉ឺនបីពាន់បួនរយ)រៀល។ ទាក់ទងនឹងការទូទាត់ថ្លៃត្រីនុយ ចុងចម្លើយបានបដិសេធ ដោយអះអាងថាក្រោយពេលចុះកិច្ចព្រមព្រៀងទទួលស្គាល់បំណុល ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៧ នៅសង្កាត់ហើយ គឺខ្លួនបានប្រគល់ត្រីក្នុងស្រះនោះ ទៅអោយដើមចោទហើយ ហេតុនេះ ខ្លួនមិនទទួលស្គាល់ថ្លៃត្រីនុយនោះទេ ហើយចំពោះការសងបំណុលជំនួសខ្លួនទៅឲ្យឈ្មោះ [redacted] មិន ក៏ខ្លួនបដិសេធដែរ ដោយហេតុថាខ្លួនមិនបានឱ្យដើមចោទសងជំនួសខ្លួនទេ។ តាមកិច្ចសន្យាខ្ចីប្រាក់រវាងដើមចោទ និងចុងចម្លើយ បានបង្ហាញថា ចុងចម្លើយបានព្រមព្រៀងប្រគល់ការលក់ត្រីក្នុងស្រះទាំងអស់ឲ្យដើមចោទឈ្មោះ [redacted] ហ៊ាង ជាអ្នកទូទាត់ប្រាក់តែប៉ុណ្ណោះ ហើយតាមកិច្ចព្រមព្រៀង ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៧ គឺចុងចម្លើយបានព្រមព្រៀងប្រគល់ត្រីក្នុងស្រះឲ្យដើមចោទដើម្បីលក់ទូទាត់បំណុល មិនមែនប្រគល់ឲ្យដើមចោទចិញ្ចឹមដើម្បីលក់ទូទាត់បំណុលនោះទេ ម្យ៉ាងទៀត តាមការអះអាងរបស់គូភាគី បញ្ជាក់ឲ្យឃើញថា ពេលចុះកិច្ចព្រមព្រៀង គឺត្រីនៅក្នុងស្រះមិនទាន់ដល់ពេលលក់នៅឡើយ ដែលមានភាពស៊ីសង្វាក់គ្នានឹងការអះអាងនិងភស្តុតាងរបស់ដើមចោទដែលបញ្ជាក់អំពីការទូទាត់ថ្លៃត្រីនុយប្រាកដមែន។ ជាមួយគ្នាដែរ តាមកិច្ចសន្យា ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៧ និងការទទួលស្គាល់របស់ចុងចម្លើយ គឺចុងចម្លើយ ពិតជាបានជំពាក់ប្រាក់ឈ្មោះ [redacted] មិន ចំនួន ៥០,០០០,០០០ (ហាសិបលាន)រៀល ពិតមែន ហើយតាមកិច្ចសន្យា ចុះថ្ងៃទី ១៧ ខែតុលា ឆ្នាំ២០១៧ និងកិច្ចព្រមព្រៀង ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៧ គឺបានបញ្ជាក់យ៉ាងច្បាស់ថា ចុងចម្លើយឈ្មោះ [redacted] ណាសុង និងដើមចោទឈ្មោះ [redacted] ហ៊ាង ពិតជាបានព្រមព្រៀងផ្ទេរបំណុល ចំនួន ៥០,០០០,០០០ (ហាសិបលាន)រៀល ដែលឈ្មោះ [redacted] ណាសុង ជំពាក់ឈ្មោះ [redacted] មិន មកឲ្យដើមចោទឈ្មោះ [redacted] ហ៊ាង ជាអ្នកសងជំនួសនៅពេលដែលចាប់ត្រីរួចប្រាកដមែន ហើយតាមភស្តុតាង ដែលដើមចោទដាក់ជូនតុលាការ ឃើញថា ពិតជាមានការទូទាត់ប្រាក់ជំពាក់រវាងដើមចោទ និងឈ្មោះ [redacted] មិន ចំនួន ៣០,០០០,០០០(សាមសិបលាន) រៀលមែន។ ហេតុនេះ តាមការអះអាងរបស់ដើមចោទ និងការពិនិត្យភស្តុតាងនានា ឃើញថា ការទាមទាររបស់ដើមចោទ គឺមានលក្ខណៈត្រឹមត្រូវ គប្បីតុលាការពិចារណា និង សម្រេចទទួលស្គាល់ការទាមទាររបស់ដើមចោទ។

៦-អ្នកតំណាងដោយអាណត្តិរបស់ដើមចោទបានថ្លែងថា ដើមចោទទាមទារការទាមទារឱ្យចុងចម្លើយបង់ការខូចខាតចំនួន ២០,០០០ (ពីរម៉ឺន) ដុល្លារអាមេរិក ដោយសារប្រាក់ដែលកូនក្តីខ្លួនឱ្យចុងចម្លើយខ្ចីជាប្រាក់ដែលខ្ចីពីធនាគារត្រូវអនុវត្តករណីយកិច្ចសងប្រាក់ដើម និងការប្រាក់ទៅធនាគារវិញ។ ម្យ៉ាងទៀត បានធ្វើឱ្យកូនក្តីខ្លួនខាតបង់ពេលវេលា និងប្រាក់ជាច្រើនក្នុងការដោះស្រាយដំណើររឿងក្តីនៅតុលាការ ឃើញថា ការអះអាងរបស់ដើមចោទបែបនេះ មានលក្ខណៈសមហេតុសមផល តែពុំមានភស្តុតាងច្បាស់លាស់នោះទេ ហេតុនេះ តុលាការគប្បីធ្វើការពិចារណាទៅតាមព្យសនកម្មជាក់ស្តែង។



Scanned with CamScanner

៧-ដើមចោទសុំតុលាការប្រកាសសាលក្រមមានអានុភាពអនុវត្តជាបណ្តោះអាសន្ន ត្រង់ចំណុចទី១នៃការទាមទារ ដោយហេតុថា ដើមចោទបានទទួលស្គាល់លើប្រាក់ដើមនេះរួចហើយ ឃើញថាការថ្លែងអះអាងរបស់ដើមចោទមានលក្ខណៈសមហេតុសមផល តុលាការគប្បីធ្វើការពិចារណា តាមមាត្រា១៩៦នៃក្រមនីតិវិធីរដ្ឋប្បវេណី។

៨-ដើមចោទសុំឲ្យចុងចម្លើយទទួលបន្ទុកប្រាក់ប្រដាប់ក្តី ឃើញថា ចុងចម្លើយជាភាគីចាញ់ក្តី ហេតុនេះ គប្បីតុលាការសម្រេចឲ្យសហចុងចម្លើយជាអ្នកទទួលបន្ទុកប្រាក់ប្រដាប់ក្តីតាមមាត្រា ៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

៩-ការទាមទារឲ្យច្រានចោលពាក្យបណ្តឹងចុះថ្ងៃទី ១៥ ខែសីហា ឆ្នាំ២០១៨ និងទាមទារឲ្យដើមចោទឈ្មោះ [redacted] ហ៊ាង សងសំណងថ្លៃរំលោភកិច្ចសន្យាព្រមព្រៀង ចុះថ្ងៃ ទី២៤ ខែតុលា ឆ្នាំ២០១៧ ធ្វើឡើងរវាងដើមចោទ និងចុងចម្លើយ ព្រមទាំងថ្លៃខាតបង់ពេលវេលា ថ្លៃចំណាយលើសេវាកម្មច្បាប់ និងការចំណាយផ្សេងៗ សរុបចំនួន ២០,០០០ (ពីរម៉ឺន)ដុល្លារអាមេរិក របស់ចុងចម្លើយឈ្មោះ [redacted] ណាសុង គឺពុំមានមូលហេតុ និងភស្តុតាងបញ្ជាក់ការទាមទារត្រឹមត្រូវ គប្បីតុលាការច្រានចោលពាក្យបណ្តឹងតប ចុះថ្ងៃទី ២០ ខែកញ្ញា ឆ្នាំ២០១៨ របស់ចុងចម្លើយ។

## **សេចក្តីសម្រេចបញ្ចប់**

១-បង្គាប់ឲ្យចុងចម្លើយឈ្មោះ [redacted] ណាសុង សងប្រាក់ជំពាក់ចំនួន $៧០,០០០ (ប្រាំពីរម៉ឺនដុល្លារអាមេរិក) មកឲ្យដើមចោទឈ្មោះ [redacted] ហ៊ាង។

២-បង្គាប់ឲ្យចុងចម្លើយឈ្មោះ [redacted] ណាសុង សងប្រាក់ជំពាក់ថ្លៃត្រីនុយចំនួន ៣៩,២៤៣,៤០០៛ (សាមសិបប្រាំបួនលានពីររយសែសិបបីពាន់បួនរយរៀល) មកឲ្យដើមចោទឈ្មោះ [redacted] ហ៊ាង។

៣-បង្គាប់ឲ្យចុងចម្លើយឈ្មោះ [redacted] ណាសុង សងការខូចខាតចំនួន $៥,០០០ (ប្រាំពាន់ដុល្លារអាមេរិក) មកឲ្យដើមចោទឈ្មោះ [redacted] ហ៊ាង ។

៤-ឲ្យចុងចម្លើយឈ្មោះ [redacted] ណាសុង ជាអ្នកទទួលបន្ទុកប្រាក់ប្រដាប់ក្តី។

៥-ច្រានចោលបណ្តឹងតបចុះថ្ងៃទី ២០ ខែកញ្ញា ឆ្នាំ២០១៨ របស់ចុងចម្លើយឈ្មោះ [redacted] ណាសុង ។

៦-សាលក្រមនេះអាចប្រកាសឲ្យអនុវត្តជាបណ្តោះអាសន្នត្រង់ចំណុចទី០១ នៃសេចក្តីសម្រេចខាងលើ ។

-សាលក្រមនេះ បានធ្វើការទាញហេតុផលដោយផ្ទាល់មាត់ និងប្រកាសជាសាធារណៈចំពោះមុខដើមចោទឈ្មោះ [redacted] ហ៊ាង និងចុងចម្លើយឈ្មោះ [redacted] ណាសុង ។

ទុកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

**ចៅក្រមជំនុំជម្រះ**

ហត្ថលេខា និងត្រា [redacted]

---

បានឃើញ
ថ្ងៃអង្គារ ៧រោច ខែមាឃ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២
សៀមរាប,ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ ២០១៩
**ចៅក្រមជំនុំជម្រះ**

[redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ថ្ងៃអង្គារ ៧រោច ខែមាឃ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២
សៀមរាប,ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ ២០១៩
**ក្រឡាបញ្ជី**

[redacted]



Scanned with CamScanner